**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៧៥ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## បែបបទនិងនីតិវិធីនៃការសុំសញ្ញាតូបនីយកម្ម

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២ នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ០៣/នស/៩៤ ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០៥/នស/៩៤ ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីអន្តោប្រវេសន៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសញ្ជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០៣/០០៩ ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០០៣ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

# សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះមានគោលបំណងធានាការអនុវត្តរាល់ការសុំចូលសញ្ជាតិខ្មែររបស់ជនបរទេសជាបុរសឬជាស្ត្រីដោយសញ្ញាតូបនីយកម្ម។

**មាត្រា ២.-**

អនុក្រឹត្យនេះមានគោលដៅកំណត់អំពីបែបបទនិងនីតិវិធីនៃការសុំចូលសញ្ជាតិខ្មែររបស់ជនបរទេសជាបុរសឬជាស្ត្រីដោយសញ្ញាតូបនីយកម្ម។

**មាត្រា ៣.-**

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តចំពោះជនបរទេសជាបុរសឬជាស្ត្រីដែលសុំចូលសញ្ជាតិខ្មែរដោយសញ្ញាតូបនីយកម្ម។

## ជំពូកទី២

## បែបបទនៃការសុំសញ្ញាតូបនីយកម្ម

**មាត្រា ៤.-**

ជនបរទេសជាបុរសឬជាស្ត្រីដែលមានបំណងសុំចូលសញ្ជាតិខ្មែរដោយសញ្ញាតូបនីយកម្ម ត្រូវបំពេញលក្ខខណ្ឌដូចមានចែងក្នុងជំពូកទី៤នៃច្បាប់ស្តីពីសញ្ជាតិ។

**មាត្រា ៥.-**

ជនបរទេសជាបុរសឬជាស្ត្រីដែលសុំចូលសញ្ជាតិខ្មែរដោយសញ្ញាតូបនីយកម្ម ត្រូវមានវត្តមាននៅក្នុងព្រះរាជាណាចក្រកម្ពុជានៅពេលដាក់ពាក្យសុំនិងត្រូវបំពេញបែបបទនៅក្រសួងមហាផ្ទៃដូចខាងក្រោម៖

- ពាក្យសុំចូលសញ្ជាតិខ្មែរចំនួន០២(ពីរ)ច្បាប់
- ជីវប្រវត្តិសង្ខេបរបស់សាមីខ្លួន មានស្នាមម្រាមដៃ ឈ្មោះ មានបិទរូបថតទំហំ៤ស.ម.គុណ៦ស.ម.ចំនួន០២(ពីរ)ច្បាប់ និងមានភ្ជាប់រូបថតចំនួន១០(ដប់)សន្លឹក។ រូបថតទាំងអស់ត្រូវថតថ្មី ចំពីមុខ គ្មានពាក់មួក និងគ្មានពាក់វ៉ែនតា
- សេចក្តីចម្លងសំបុត្រកំណើត ដែលចេញដោយអាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសរបស់សាមីខ្លួនជនបរទេសចំនួន០២(ពីរ)ច្បាប់
- លិខិតឆ្លងដែនថតចម្លងនិងទិដ្ឋាការថតចម្លងរបស់សាមីខ្លួនដែលនៅមានសុពលភាពចាប់ពីថ្ងៃចូលដំបូងរហូតដល់ថ្ងៃចូលចុងក្រោយក្នុងព្រះរាជាណាចក្រកម្ពុជាចំនួន០២(ពីរ)ច្បាប់
- លិខិតបញ្ជាក់ទីលំនៅនិងលិខិតបញ្ជាក់គំនិតមារយាទចេញដោយមេឃុំឬចៅសង្កាត់០១(មួយ)ច្បាប់
- លិខិតថ្កោលទោសមានសុពលភាពចេញដោយក្រសួងយុត្តិធម៌នៃព្រះរាជាណាចក្រកម្ពុជា០១(មួយ)ច្បាប់

- លិខិតថ្កោលទោសមានសុពលភាពចេញដោយអាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសរបស់សាមីខ្លួន ជនបរទេស០១(មួយ)ច្បាប់ដោយមានបញ្ជាក់ពីស្ថានទូតឬស្ថានតំណាងរបស់ខ្លួន
- ខិតបញ្ជាក់សុខភាពនិងកាយសម្បទាចេញដោយសមត្ថកិច្ចសុខាភិបាលចំនួន០២(ពីរ)ច្បាប់
- ប័ណ្ណស្នាក់នៅអចិន្ត្រៃយ៍ចេញដោយការិយាល័យអន្តោប្រវេសន៍នៃស្នងការដ្ឋាននគរបាលរាជធានី ខេត្ត ០១(មួយ)ច្បាប់ លើកលែងតែជនបរទេសដែលបានកំណត់សិទ្ធិដូចមានចែងក្នុងមាត្រា១០ មាត្រា១១ មាត្រា១២ និងមាត្រា១៣នៃច្បាប់ស្តីពីសញ្ជាតិ។

**មាត្រា ៦.-**

ការសុំចូលសញ្ជាតិខ្មែររបស់ជនបរទេសជាបុរសឬជាស្ត្រីដោយសញ្ជាតូបនីយកម្ម ត្រូវបង់កម្រៃសេវារដ្ឋបាល។

កម្រៃសេវារដ្ឋបាលនៃការសុំចូលសញ្ជាតិខ្មែរនេះ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃនិងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## ជំពូកទី៣
## នីតិវិធីនៃការសុំសញ្ជាតូបនីយកម្ម

**មាត្រា ៧.-**

នីតិវិធីនៃការទទួលនិងការពិនិត្យលើសំណុំឯកសារសុំចូលសញ្ជាតិខ្មែរ និងការប្រឡងសុំចូលសញ្ជាតិខ្មែរដោយសញ្ជាតូបនីយកម្មរបស់ជនបរទេសជាបុរសឬជាស្ត្រី ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

**មាត្រា ៨.-**

ការផ្តល់សញ្ជាតិខ្មែររបស់ជនបរទេសជាបុរសឬជាស្ត្រីដោយសញ្ជាតូបនីយកម្ម ត្រូវសម្រេចដោយព្រះរាជក្រឹត្យតាមសំណើរបស់នាយករដ្ឋមន្ត្រី បន្ទាប់ពីមានសេចក្តីស្នើសុំរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

**មាត្រា ៩.-**

ជនបរទេសជាបុរសឬជាស្ត្រីដែលព្រះមហាក្សត្របានប្រទានសញ្ជាតិខ្មែរ ត្រូវធ្វើសម្បថនៅចំពោះមុខតុលាការកំពូល។

ព្រះរាជក្រឹត្យផ្តល់សញ្ជាតិខ្មែរ ត្រូវប្រគល់ជូនសាមីខ្លួនបន្ទាប់ពីបានធ្វើសម្បថរួច ដោយក្រសួងមហាផ្ទៃ។

ខ្លឹមសារនៃសម្បថមានអត្ថន័យដូចតទៅ៖

« ខ្ញុំសូមសច្ចាជាឱឡារិកថាខ្ញុំមានភក្តីភាពនិងសេចក្តីស្នេហាចំពោះជាតិមាតុភូមិកម្ពុជារបស់ខ្ញុំ ហើយប្តេជ្ញាធ្វើពលិកម្មគ្រប់បែបយ៉ាងដើម្បីការពារនិងគោរពរដ្ឋធម្មនុញ្ញនិងច្បាប់នៃព្រះរាជាណាចក្រកម្ពុជាទាំងក្នុងពេលបច្ចុប្បន្នទាំងក្នុងពេលអនាគត »។

« ខ្ញុំសូមប្តេជ្ញាជាឱឡារិកថានឹងតាំងខ្លួនជាពលរដ្ឋខ្មែរដ៏ល្អ ហើយហ៊ានលះបង់គ្រប់បែបយ៉ាងដើម្បីចូលរួមចំណែកក្នុងការការពារខឿនឯករាជ្យជាតិ អធិបតេយ្យជាតិ បូរណភាពទឹកដី សន្តិភាព ស្ថិរភាព សន្តិសុខ និងការអភិវឌ្ឍសេដ្ឋកិច្ច សង្គម ព្រមទាំងលើកកម្ពស់កិត្យានុភាព នៃព្រះរាជាណាចក្រកម្ពុជា ទាំងក្នុងពេលបច្ចុប្បន្ន ទាំងក្នុងពេលអនាគត »។

## ជំពូកទី៤
## អវសានប្បញ្ញត្តិ

**មាត្រា ១០.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ១១.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ២០១៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**បានយកសេចក្តីគោរពជូន**
**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**
**នាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា**

**ស ខេង**
**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**កន្លែងទទួល៖**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- តុលាការកំពូលនិងមហាអយ្យការអមតុលាការកំពូល
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- សាលារាជធានី-ខេត្ត
- ដូចមាត្រា ១១
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ